ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខៈ ១១០៩ អយក.ប្រក

# ប្រកាស
# ស្តីពី
# ឯកសណ្ឋានបំពេញការងាររបស់
# គ្រូបង្រៀនកម្រិតឧត្តមនិងគ្រូបង្រៀនកម្រិតមូលដ្ឋាន

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៤០ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០១ ស្តីពីសហលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៤១ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០១ ស្តីពីសហលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៧/៣២៥ ចុះថ្ងៃទី១ ខែសីហា ឆ្នាំ២០០៧ ស្តីពីរូបសញ្ញាអប់រំ យុវជន និងកីឡា សញ្ញាសក្តិ ឯកសណ្ឋាន និងសក្តិខ្វាស់លើអាវ ឬក្រមាពានា សម្រាប់មន្ត្រីអប់រំក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម និងក្របខ័ណ្ឌគ្រូកម្រិតមូលដ្ឋាន
- បានឃើញអនុក្រឹត្យលេខ១២៦ អនក្រ.បក ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន
- បានឃើញអនុក្រឹត្យលេខ១០១ អនក្រ.បក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- តាមការចាំបាច់របស់ក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១ .-**

ប្រកាសនេះ កំណត់អំពីឯកសណ្ឋានបំពេញការងាររបស់គ្រូបង្រៀនកម្រិតឧត្តមនិងគ្រូបង្រៀនកម្រិតមូលដ្ឋានដែលបម្រើការងារនៅគ្រប់ឋានានុក្រមរដ្ឋបាលអប់រំ ទាំងថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងគ្រឹះស្ថានសិក្សាសាធារណៈគ្រប់កម្រិត ដើម្បីលើកកម្ពស់សីលធម៌ សេចក្តីថ្លៃថ្នូរ គុណភាព ប្រសិទ្ធភាពការងារ តម្លាភាព និងការទទួលខុសត្រូវក្នុងការអនុវត្តតួនាទីភារកិច្ច។

## ជំពូកទី ២

## សញ្ញាសក្តិស្មានិងឯកសណ្ឋានរបស់ គ្រូបង្រៀនកម្រិតឧត្តមនិងគ្រូបង្រៀនកម្រិតមូលដ្ឋាន

**ប្រការ២ .-**

សញ្ញាសក្តិស្មារបស់គ្រូបង្រៀនកម្រិតឧត្តម មានរូបនិងក្បាច់ផ្កាភ្ញី ពណ៌មាស ព្រមទាំងមានផ្ទៃ ទម្រង់ ខ្នាត ដូចមានចែងក្នុងព្រះរាជក្រឹត្យលេខនស/រកត/០៨០៧/៣២៥ ចុះថ្ងៃទី១ ខែសីហាឆ្នាំ២០០៧ ស្តីពីរូបសញ្ញាអប់រំ យុវជន និងកីឡា សញ្ញាសក្តិ ឯកសណ្ឋាន សក្តិខ្វាស់លើអាវ ឬក្រមាពានា សម្រាប់មន្ត្រីអប់រំក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម និងក្របខ័ណ្ឌគ្រូកម្រិតមូលដ្ឋាន មានដូចរូបទី១ ទី២ និងទី៣ ក្នុងឧបសម្ព័ន្ធទី៤ នៃប្រកាសនេះ។

សញ្ញាសក្តិស្មារបស់គ្រូបង្រៀនកម្រិតមូលដ្ឋាន មានរូបនិងក្បាច់ផ្កាភ្ញី ពណ៌ប្រាក់ ព្រមទាំងមានផ្ទៃ ទម្រង់ ខ្នាត ដូចមានចែងក្នុងព្រះរាជក្រឹត្យលេខនស/រកត/០៨០៧/៣២៥ ចុះថ្ងៃទី១ ខែសីហាឆ្នាំ២០០៧ ស្តីពីរូបសញ្ញាអប់រំ យុវជន និងកីឡា សញ្ញាសក្តិ ឯកសណ្ឋាន សក្តិខ្វាស់លើអាវ ឬក្រមាពានា សម្រាប់មន្ត្រីអប់រំក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តមនិងក្របខ័ណ្ឌគ្រូកម្រិតមូលដ្ឋាន មានដូចរូបទី១ ទី២ និងទី៣ក្នុងឧបសម្ព័ន្ធទី៥នៃប្រកាសនេះ។

**ប្រការ៣ .-**

ឯកសណ្ឋានបំពេញការងាររបស់គ្រូបង្រៀនកម្រិតឧត្តមនិងគ្រូបង្រៀនកម្រិតមូលដ្ឋាន ត្រូវបានកំណត់ដូចខាងក្រោម៖

- **អាវ** សឺមីដៃវែងឬខ្លី ពណ៌ស កឱប មានហោប៉ៅពីរសងខាង មានគម្របស្លឹកពោធិ៍ មានប៉ូលស្មាពីរសងខាង។ ប៉ូលស្មាសងខាងត្រូវពាក់សក្តិស្មា តាមឋានន្តរសក្តិនៃប្រភេទក្របខ័ណ្ឌនីមួយៗ ដូចមានក្នុងឧបសម្ព័ន្ធទី៤ និងទី៥ នៃប្រកាសនេះ។
- **ខោ ឬសំពត់** ពណ៌ទឹកប៊ិចក្រមៅ ដែល៖
  - **សម្រាប់បុរស៖** ខោជើងវែង មានហោប៉ៅក្រោយមួយ មានគម្របហើយដេរបង្កប់ និងមានហោប៉ៅចំហៀងពីរ។
  - **សម្រាប់នារី៖** សំពត់បត់វែង។

គំរូឯកសណ្ឋានបំពេញការងាររបស់គ្រូបង្រៀនកម្រិតឧត្តម មានដូចក្នុងឧបសម្ព័ន្ធទី២នៃប្រកាសនេះ។
គំរូឯកសណ្ឋានបំពេញការងាររបស់គ្រូបង្រៀនកម្រិតមូលដ្ឋាន មានដូចក្នុងឧបសម្ព័ន្ធទី៣នៃប្រកាសនេះ។

- **រូបសញ្ញាក្រសួងអប់រំ យុវជន និងកីឡា ៖** សញ្ញាក្រសួងអប់រំ យុវជន និងកីឡា មានរាងមូលព័ទ្ធជុំវិញក្បាច់ភ្ញីទេសពណ៌មាស មានទទឹងប្រវែង ៤ភាគ៥ នៃកម្ពស់ ផ្នែកខាងក្នុងរង្វង់មូល មានផ្ទៃពណ៌ផ្ទៃមេឃដែលរំលេចដោយកាំរស្មីពណ៌មាសចាំងបំភ្លឺគ្រប់ទិសទី នៅខាងក្រោមចំកណ្តាល មានកំណាត់ខ្សែបូពណ៌ផ្ទៃមេឃនិងគែមពណ៌មាសដែលចារឹកដោយអក្សរពណ៌មាសថា **ក្រសួងអប់រំ យុវជន និងកីឡា** នៅចំកណ្តាលពីលើកម្រងផ្កាក្បាច់ភ្ញីទេសមានរង្វង់មូលទ្រភ្លើងគុបពណ៌មាស។
- **ស្លាកឈ្មោះ៖** ធ្វើពីជ័រវឹងភ្លឺ ពណ៌ទឹកប៊ិចក្រមៅ អក្សរពណ៌មាស បកបិទលើហោប៉ៅអាវខាងឆ្វេងដែល៖
  - នៅផ្នែកខាងឆ្វេងផ្នែកខាងលើ មានស្លាករូបសញ្ញាក្រសួងអប់រំ យុវជន និងកីឡា សម្រាប់សម្គាល់អង្គគ្រូបង្រៀន។
  - ផ្នែកខាងស្តាំមានផ្នែកខាងលើមានឈ្មោះអង្គភាព ផ្នែកកណ្តាលមានឈ្មោះជាអក្សរខ្មែរ អក្សរឡាតាំង និងផ្នែកខាងក្រោមមានអត្តលេខមន្ត្រីរាជការ។

  រូបគំនូស្លាកឈ្មោះ មានដូចរូបទី២ ក្នុងឧបសម្ព័ន្ធទី៦ នៃប្រកាសនេះ។
- **បារ៉ែត** (សញ្ញាសម្គាល់គ្រឿងឥស្សរិយយស)៖ ត្រូវពាក់នៅលើហោប៉ៅអាវខាងស្តាំ មានដូចរូបទី១ ក្នុងឧបសម្ព័ន្ធទី៦ នៃប្រកាសនេះ។

**ប្រការ៤.-**

គ្រូបង្រៀនកម្រិតឧត្តមនិងគ្រូបង្រៀនកម្រិតមូលដ្ឋាន ដែលបម្រើការងារនៅគ្រប់ឋានានុក្រមរដ្ឋបាលអប់រំទាំងថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងគ្រឹះស្ថានសិក្សាសាធារណៈគ្រប់កម្រិត ត្រូវស្លៀកពាក់ឯកសណ្ឋានសម្រាប់ចូលរួមកិច្ចប្រជុំ សិក្ខាសាលា សន្និបាត បេសកកម្ម និងពិធីផ្សេងៗដូចមានកំណត់ក្នុងប្រកាសនេះ។ ប្រធានអង្គភាព ឬគណៈគ្រប់គ្រងគ្រឹះស្ថានសិក្សា មានសិទ្ធិកំណត់ការស្លៀកពាក់ឯកសណ្ឋានដូចមានកំណត់ក្នុង

ប្រកាសនេះសម្រាប់ស្លៀកពាក់ក្នុងសកម្មភាពផ្សេងៗទៀតនៃការបំពេញការងារ មានដូចរូបទី១និងទី២ក្នុងឧបសម្ព័ន្ធទី១ នៃប្រកាសនេះ។

គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាសាធារណៈ មានសិទ្ធិរៀបចំនិងកំណត់ឯកសណ្ឋានសម្រាប់គ្រូបង្រៀនកម្រិតឧត្តមនិងគ្រូបង្រៀនកម្រិតមូលដ្ឋាន ស្លៀកពាក់បំពេញការងារប្រចាំថ្ងៃនៅក្នុងគ្រឹះស្ថានសិក្សារបស់ខ្លួនក្នុងទម្រង់ ឬពណ៌ផ្សេងទៀតបាន ដោយបំពាក់ស្លាកឈ្មោះដែលមានរូបសញ្ញាអប់រំ យុវជន និងកីឡា ដូចរូបទី២ក្នុងឧបសម្ព័ន្ធទី៦ នៃប្រកាសនេះ។

## ជំពូកទី៣
## អវសានប្បញ្ញត្តិ

**ប្រការ៥ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ៦ .-**

អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានឧត្តមសិក្សា អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំ អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយនិងផែនការ អគ្គនាយកនៃអគ្គនាយកដ្ឋានយុវជន អគ្គនាយកនៃ អគ្គនាយកដ្ឋានកីឡា អគ្គនាយកនៃអគ្គនាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធានគ្រប់អង្គភាពពាក់ព័ន្ធ ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ប្រធានការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងនាយកគ្រឹះស្ថានសិក្សាសាធារណៈត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ១១រោច ខែ អាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ២០២៥

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី
- គ្រប់អង្គភាពក្រោមឱវាទក្រសួង អ.យ.ក

"ដើម្បីជូនជ្រាបជាព័ត៌មាន"

- ដូចប្រការ៦

"ដើម្បីអនុវត្ត"

- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ នា.នីតិកម្ម

ឧបសម្ព័ន្ធទី១ នៃប្រកាសលេខ...១១០៩...អយក.ប្រក ចុះថ្ងៃទី...២១....ខែ...កក្កដា.....ឆ្នាំ២០២៥
ស្តីពីឯកសណ្ឋានបំពេញការងាររបស់គ្រូបង្រៀនកម្រិតឧត្តមនិងគ្រូបង្រៀនកម្រិតមូលដ្ឋាន

**រូបទី១ ឯកសណ្ឋានបំពេញការងារសម្រាប់គ្រូបង្រៀនកម្រិតឧត្តម**



រូបទី២ ឯកសណ្ឋានបំពេញការងារសម្រាប់គ្រូបង្រៀនកម្រិតមូលដ្ឋាន



ព្រះរាជាណាចក្រកម្ពុជា
ក្រសួងអប់រំយុវជននិងកីឡា

ឧបសម្ព័ន្ធទី២ នៃប្រកាសលេខ...១១០៩...អយក.ប្រក ចុះថ្ងៃទី.២១.......ខែ.កក្កដា.....ឆ្នាំ២០២៥
ស្ដីពីឯកសណ្ឋានបំពេញការងាររបស់គ្រូបង្រៀនកម្រិតឧត្ដមនិងគ្រូបង្រៀនកម្រិតមូលដ្ឋាន

**គំរូឯកសណ្ឋានបំពេញការងារសម្រាប់គ្រូបង្រៀនកម្រិតឧត្ដម (បុរស)**

រូបទី១ អាវដៃវែងសម្រាប់បុរស



រូបទី២ ខោជើងវែងបត់សម្រាប់បុរស



រូបទី៣ ស្បែកជើងសម្រាប់បុរស



ព្រះរាជាណាចក្រកម្ពុជា * ក្រសួងអប់រំ យុវជន និងកីឡា *

## គំរូឯកសណ្ឋានបំពេញការងារសម្រាប់គ្រូបង្រៀនកម្រិតឧត្តម (នារី)

រូបទី១ អាវដៃវែងសម្រាប់នារី



រូបទី២ សំពត់វែងបត់សម្រាប់នារី



រូបទី៣ ស្បែកជើងសម្រាប់នារី



ឧបសម្ព័ន្ធទី៣ នៃប្រកាសលេខ.....១១០៩.....អយក.ប្រក ចុះថ្ងៃទី.....២១.....ខែ.....កក្កដា.....ឆ្នាំ២០២៥
ស្តីពីឯកសណ្ឋានបំពេញការងាររបស់គ្រូបង្រៀនកម្រិតឧត្តមនិងគ្រូបង្រៀនកម្រិតមូលដ្ឋាន

**គំរូឯកសណ្ឋានបំពេញការងារសម្រាប់គ្រូបង្រៀនកម្រិតមូលដ្ឋាន (បុរស)**

**រូបទី១ អាវដៃវែងសម្រាប់បុរស**



**រូបទី២ ខោជើងវែងបត់សម្រាប់បុរស**



**រូបទី៣ ស្បែកជើងសម្រាប់បុរស**



## គំរូឯកសណ្ឋានបំពេញការងារសម្រាប់គ្រូបង្រៀនកម្រិតមូលដ្ឋាន (នារី)

រូបទី១ អាវដៃវែងសម្រាប់នារី



រូបទី២ សំពត់វែងបត់សម្រាប់នារី



រូបទី៣ ស្បែកជើងសម្រាប់នារី



ឧបសម្ព័ន្ធទី៤ នៃប្រកាសលេខ ១១០៩ អយក.ប្រក ចុះថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ២០២៥
ស្តីពីឯកសណ្ឋានបំពេញការងាររបស់គ្រូបង្រៀនកម្រិតឧត្តមនិងគ្រូបង្រៀនកម្រិតមូលដ្ឋាន

## រូបទី១ សក្តិស្នា សម្រាប់គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស

សក្តិស្នា



## រូបទី២ សក្តិស្នា សម្រាប់គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ

សក្តិស្នា



## រូបទី៣ សក្តិស្នា សម្រាប់គ្រូបង្រៀនកម្រិតឧត្តម

សក្តិស្នា



ព្រះរាជាណាចក្រកម្ពុជា * ក្រសួងអប់រំយុវជននិងកីឡា *

ឧបសម្ព័ន្ធទី៥ នៃប្រកាសលេខ.១១០៨.....អយក.ប្រក ចុះថ្ងៃទី.២១.....ខែ.កក្កដា.....ឆ្នាំ២០២៥
ស្តីពីឯកសណ្ឋានបំពេញការងាររបស់គ្រូបង្រៀនកម្រិតឧត្តមនិងគ្រូបង្រៀនកម្រិតមូលដ្ឋាន

**រូបទី១ សក្តិស្មា សម្រាប់គ្រូបង្រៀនកម្រិតមូលដ្ឋានដើមខ្សែពិសេស**

សក្តិស្មា



**រូបទី២ សក្តិស្មា សម្រាប់គ្រូបង្រៀនកម្រិតមូលដ្ឋានដើមខ្សែ**

សក្តិស្មា



**រូបទី៣ សក្តិស្មា សម្រាប់គ្រូបង្រៀនកម្រិតមូលដ្ឋាន**

សក្តិស្មា



ឧបសម្ព័ន្ធទី៦ នៃប្រកាសលេខ...១១០៩.....អយក.ប្រក ចុះថ្ងៃទី...២១......ខែ...កក្កដា.....ឆ្នាំ២០២៥
ស្តីពីឯកសណ្ឋានបំពេញការងាររបស់គ្រូបង្រៀនកម្រិតឧត្តមនិងគ្រូបង្រៀនកម្រិតមូលដ្ឋាន

**រូបទី១**

**បារ៉ែត ( សញ្ញាសម្គាល់គ្រឿងឥស្សរិយយស )**



**រូបទី២**

**ស្លាកឈ្មោះ**

